**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## ផ្ញើជូន
## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសដ៏មង្គលសួស្តីប្រសើរថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃការទទួលអំណរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ សូមទទួលបាននូវសព្ទសាធុការពរជ័យ សិរីមង្គល ប្រកបដោយសេចក្តីសុខសម្រេចបានជោគជ័យនូវភារកិច្ច និងទទួលបានកិត្តិយសកេរ្តិ៍ឈ្មោះជូនជាតិមាតុភូមិ។

នាឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះចំពោះការលះបង់ខិតខំពុះពារជម្នះគ្រប់ឧបសគ្គ និងការលំបាកទាំងឡាយ ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីជាតិមាតុភូមិ ការពារសន្តិសុខជាតិ ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខដុមរមនាជូនប្រជាជនទាំងក្នុងជាតិនិងអន្តរជាតិ ដែលជាក្តីមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរបស់កងយោធពលខេមរភូមិន្ទយើងទាំងមូល។

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ជាទីស្នេហា !**

ជាថ្មីម្តងទៀតក្នុងពិធីបុណ្យចូលឆ្នាំថ្មីនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសួរសុខទុក្ខដល់យោធិន **ជំងឺ របួស ពិការ** ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យឆាប់បានជាសះស្បើយពីជំងឺ ព្រមទាំងអតីតយុទ្ធជននិងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងរឹងមាំ និងមានជីវភាពរស់នៅធូរធាប្រកបដោយសុភមង្គលរុងរឿង។

សូមផ្ញើជូន មេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព នាយទាហាន នាយទាហានរង និងពល-ទាហាន ក្នុងកងយោធពលខេមរភូមិន្ទទាំងអស់ ព្រមទាំងសិក្ខាកាមដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗ នៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាព ក្រោមកិច្ចសហប្រតិបត្តិការ

អន្តរជាតិរបស់អង្គការសហប្រជាជាតិ ព្រមទាំងក្រុមគ្រួសារ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍កម្លាំងមាំមួន ខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ ប្រកបទៅដោយសេចក្តីសុខសប្បាយ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចថ្មីៗបន្តទៀតជូនជាតិមាតុភូមិយើង និងសុំចៀសផុតពីគ្រោះចង្រៃនៃការឆ្លងរីករាលដាលពីជំងឺកូវីដ-១៩ ដ៏កាចសាហាវនេះ ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**